PUB 195USKH (11-09) Khmer

pennsylvania
DEPARTMENT OF TRANSPORTATION

# សំណើតម្រូវការពីអត្តសញ្ញាណប័ណ្ណ និងពីការស្នាក់នៅ សម្រាប់ពលរដ្ឋសហរដ្ឋអាមេរិក

ជាផ្នែកនៃកិច្ចប្រឹងប្រែងទូទាំងប្រទេស ដើម្បីពង្រឹងនូវការចេញឯកសារបញ្ជាក់អត្តសញ្ញាណដែលសុវត្ថិភាព រដ្ឋផេនស៊ីលវ៉ានីញ៉ាតម្រូវឱ្យផ្តល់ឯកសារដូចតទៅនេះពីពលរដ្ឋសហរដ្ឋអាមេរិកដែលដាក់ពាក្យសុំប័ណ្ណបើកបរនៅរដ្ឋផេនស៊ីលវ៉ានីញ៉ា លិខិតអនុញ្ញាតរៀនបើកបរ ឬអត្តសញ្ញាណប័ណ្ណ ឬពលរដ្ឋសហរដ្ឋអាមេរិក ដែលផ្ទេរនូវប័ណ្ណបើកបរឬអត្តសញ្ញាណប័ណ្ណក្រៅរដ្ឋ ។

## លក្ខខណ្ឌនានានៃអាយុសម្រាប់ប័ណ្ណសម្គាល់ពលរដ្ឋ សអរ

នៃបុគ្គលម្នាក់ៗ ដែលដាក់ពាក្យសុំប័ណ្ណបើកបរមិនមែនជំនួញ ត្រូវតែមានអាយុយ៉ាងតិចណាស់ 16 ឆ្នាំ។

បុគ្គលនានា ដែលដាក់ពាក្យសុំអត្តសញ្ញាណប័ណ្ណ ត្រូវតែមានអាយុយ៉ាងតិចណាស់ 10 ឆ្នាំ។

បុគ្គលនានា ដែលផ្ទេរប័ណ្ណបើកបរមិនមែនជំនាញ ត្រូវតែមានអាយុយ៉ាងតិចណាស់ 16 ឆ្នាំកន្លះ។

បុគ្គលផ្ទាល់ខ្លួនម្នាក់ៗ ដែលដាក់ពាក្យសុំលិខិតអនុញ្ញាតសិក្សា ត្រូវតែមានអាយុយ៉ាងតិចណាស់ 16 ឆ្នាំ។

លិខិតអនុញ្ញាតសិក្សាក្រៅស្រុក មិនអាចត្រូវបានផ្ទេរ ទៅកាន់រដ្ឋផេនស៊ីលវ៉ានីញ៉ានោះទេ។

បុគ្គលនានា ដែលដាក់ពាក្យសុំ ឬដែលផ្ទេរប័ណ្ណបើកបរ ត្រូវតែមានអាយុយ៉ាងតិចណាស់ 18 ឆ្នាំ សម្រាប់ការបើកបរក្នុងរដ្ឋ ឬមានអាយុយ៉ាងតិចណាស់ 21 ឆ្នាំ ឬច្រើនជាងនេះ សម្រាប់ការបើកបរឆ្លងរដ្ឋ។

## អ្នករស់នៅក្នុងរដ្ឋផេនស៊ីលវ៉ានីញ៉ា

ប្រសិនបើលោកអ្នកស្ថិតក្រោមអាយុ 18 ឆ្នាំ និងជាអ្នករស់នៅក្នុងរដ្ឋផេនស៊ីលវ៉ានីញ៉ា លោកអ្នកនឹងចាំបាច់ត្រូវបង្ហាញ៖

- ❑ សំណុំបែបបទមួយនៃអត្តសញ្ញាណប័ណ្ណពីបញ្ជី A
- ❑ និង ប័ណ្ណសន្តិសុខសង្គមរបស់លោកអ្នក។

ប្រសិនបើលោកអ្នកមានអាយុ 18 ឆ្នាំ ឬច្រើនជាងនេះ ហើយលោកអ្នកជាអ្នករស់នៅក្នុងរដ្ឋផេនស៊ីលវ៉ានីញ៉ា លោកអ្នកត្រូវបង្ហាញ៖

- ❑ សំណុំបែបបទចំនួនមួយនៃអត្តសញ្ញាណប័ណ្ណពីបញ្ជី A
- ❑ សំណុំបែបបទចំនួនពីរ នៃភស្តុតាងដែលបានពីការស្នាក់នៅពីបញ្ជី B និង
- ❑ ប័ណ្ណសន្តិសុខសង្គមរបស់លោកអ្នក។

## អ្នករស់នៅថ្មីក្នុងរដ្ឋផេនស៊ីលវ៉ានីញ៉ា

អ្នករស់នៅថ្មីក្នុងរដ្ឋផេនស៊ីលវ៉ានីញ៉ា ដែលកាន់ប័ណ្ណបើកបរនៅមានសុពលភាពពីរដ្ឋដទៃក្នុងសហរដ្ឋអាមេរិក ត្រូវតែមកទទួលប័ណ្ណបើកបររដ្ឋផេនស៊ីលវ៉ានីញ៉ាក្នុងរយៈពេល 60 ថ្ងៃ បន្ទាប់ពីផ្លាស់ទីមក រដ្ឋផេនស៊ីលវ៉ានីញ៉ា និងប្រគល់នូវប័ណ្ណបើកបរ ឬអត្តសញ្ញាណប័ណ្ណក្រៅរដ្ឋ។

ប្រសិនបើលោកអ្នកជាអ្នករស់នៅថ្មីក្នុងរដ្ឋផេនស៊ីលវ៉ានីញ៉ា ហើយប័ណ្ណបើកបរនៃរដ្ឋមុនរបស់លោកអ្នកបានផុតកំណត់អស់រយៈលើសពី 6 ខែ ឬអ្នកមិនមានប័ណ្ណបើកបរនៃរដ្ឋមុនរបស់លោកអ្នក លោកអ្នកនឹងត្រូវបានតម្រូវឱ្យ ដាក់ពាក្យសុំលិខិតអនុញ្ញាតរៀននៅរដ្ឋផេនស៊ីលវ៉ានីញ៉ា និង ទទួលយកនូវការប្រឡងមើល ប្រឡងចំណេះដឹង និង ប្រឡងបើកបរលើផ្លូវ។

អ្នករស់នៅថ្មីក្នុងរដ្ឋផេ នស៊ីលវ៉ានីញ៉ា ដែលមានប័ណ្ណបើកបរនៅមានសុពលភាព ពីប្រទេសព័រតូរីកូ ឬដែនដីសហរដ្ឋអាមេរិក ឬដែលការកាន់កាប់អាចផ្ទេរប័ណ្ណបើកបរមានសុពលភាពរបស់ពួកគេ ទៅជាប័ណ្ណបើកបរមិនមែនជំនួញរដ្ឋផេនស៊ីលវ៉ានីញ៉ា។

អ្នករស់នៅថ្មីក្នុងរដ្ឋផេនស៊ីលវ៉ានីញ៉ាដែលមានប័ណ្ណបើកបរជំនួញនៅមានសុពលភាព (CDL) ពីរដ្ឋដទៃក្នុងសហរដ្ឋអាមេរិក អាចផ្ទេរប័ណ្ណបើកបរជំនួញរបស់ពួកគេមកជាប័ណ្ណបើកបរជំនួញក្នុងរដ្ឋផេនស៊ីលវ៉ានីញ៉ា។

ប្រសិនបើលោកអ្នកស្ថិតក្រោម អាយុ 18 ឆ្នាំ និងជាអ្នករស់នៅថ្មីក្នុងរដ្ឋផេនស៊ីលវ៉ានីញ៉ា លោកអ្នកនឹងត្រូវបង្ហាញៈ

- ❑ សំណុំបែបបទអត្តសញ្ញាណប័ណ្ណមួយពីបញ្ជី A
- ❑ ប័ណ្ណសន្តិសុខសង្គមរបស់លោកអ្នក និង
- ❑ ប័ណ្ណបើកបរក្រៅរដ្ឋរបស់លោកអ្នក និង/ឬ អត្តសញ្ញាណប័ណ្ណ។

ប្រសិនបើលោកអ្នកស្ថិតក្រោមអាយុ 18 ឆ្នាំ ឬច្រើនជាងនេះ ហើយលោកអ្នកជាអ្នករស់នៅថ្មីក្នុងរដ្ឋផេនស៊ីលវ៉ានីញ៉ា លោកអ្នកនឹងត្រូវបង្ហាញៈ

- ❑ សំណុំបែបបទមួយ នៃអត្តសញ្ញាណប័ណ្ណពីបញ្ជី A
- ❑ សំណុំបែបបទពីរនៃភស្តុតាងនៃការរស់នៅពីបញ្ជី B
- ❑ ប័ណ្ណសន្តិសុខសង្គមរបស់លោកអ្នក និង
- ❑ ប័ណ្ណបើកបរក្រៅរដ្ឋរបស់លោកអ្នក និង/ឬអត្តសញ្ញាណប័ណ្ណ។

<u>**បញ្ជី A**</u>:

## សំណុំបែបបទដែលអាចទទួលយកបាននានានៃអត្តសញ្ញាណប័ណ្ណ សម្រាប់ពលរដ្ឋ សអរៈ

- ❑ សំបុត្រកំណើតដោយមានការបោះត្រា *(ស.អាមេរិក ដែលចេញឱ្យដោយភ្នាក់ងាររដ្ឋាភិបាលដែលត្រូវបានផ្តល់សិទ្ធិ រាប់បញ្ចូលទាំង ដែនដី សអរ ឬប្រទេសព័រតូរីកូ សំបុត្រកំណើតដែលមិនមែនជាពលរដ្ឋ សអរ នឹងមិនត្រូវបានគេ ទទួលយកទេយកទេ។)*
- ❑ សំបុត្របញ្ជាក់ពីសញ្ជាតិអាមេរិក (N-560 សំណុំបែបបទ INS)
- ❑ សំបុត្របញ្ជាក់ពីការចូលសញ្ជាតិ (N-550 ឬ N-570 សំណុំបែបបទ N-560)
- ❑ លិខិតឆ្លងដែន សអរ ដែលនៅមានសុពលភាព

***ចំណាំៈ លិខិតឆ្លងដែនដែលនៅមានសុពលភាព និងឯកសារច្បាប់ដើម តែប៉ុណ្ណោះនឹងត្រូវបានគេទទួលយក។ ប្រសិនបើឈ្មោះនៅលើឯកសារច្បាប់ដើមខុសគ្នាពីឈ្មោះរបស់លោកអ្នកនាពេលបច្ចុប្បន្ន លោកអ្នកត្រូវតែផ្តល់ឯកសារបញ្ជាក់នានាដែលភ្ជាប់ឈ្មោះ ដូចជាសំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើម ក្រឹត្យលែងលះ ឬឯកសារដីកាបញ្ជាតុលាការ។***

<u>**បញ្ជី B:**</u>

## បញ្ជីឯកសារធ្វើភស្តុតាងលើកន្លែងស្នាក់នៅ ដែលត្រូវបានគេទទួលយក សម្រាប់អ្នកដាក់ពាក្យដែលមានអាយុ 18 ឆ្នាំ ឬច្រើនជាងៈ

- ❑ របាយការណ៍ពន្ធលើកិច្ចសន្យាជួល
- ❑ កិច្ចព្រមព្រៀងនានា
- ❑ ឯកសារអចលនទ្រព្យនានា
- ❑ សំណុំបែបបទ W-2
- ❑ លិខិតអនុញ្ញាតប្រើប្រាស់អាវុធបច្ចុប្បន្ន
- ❑ វិក្កយបត្រប្រើប្រាស់សេវាសាធារណៈសំខាន់ៗបច្ចុប្បន្នៈ *(ទឹក ឧស្ម័ន អគ្គិសនី ខ្សែកាប ។ល។)*

**ចំណាំ:** សម្រាប់វិក្កយបត្រប្រើប្រាស់ សេវាសាធារណៈសំខាន់ៗបច្ចុប្បន្នៈ វិក្កយបត្រតាមទូរស័ព្ទចល័ត ឬឧបករណ៍ឱ្យសញ្ញាទូរស័ព្ទ មិនអាចទទួលយកបាននោះទេ។ ប្រសិនបើលោកអ្នករស់នៅជាមួយអ្នកណាម្នាក់ ហើយមិនមានវិក្កយបត្រជាឈ្មោះរបស់លោកអ្នក លោកអ្នកនឹង ត្រូវផ្តល់ភស្តុតាងចំនួនពីរពីទីកន្លែងរស់នៅរបស់លោកអ្នក។ ភស្តុតាងមួយ គឺការនាំយកនូវបុគ្គលម្នាក់ដែលលោក អ្នករស់នៅជាមួយ និងប័ណ្ណបើកបរ ឬអត្តសញ្ញាណប័ណ្ណមានបិទរូបថតទៅកាន់មណ្ឌលធ្វើប័ណ្ណបើកបរ។ លើសពីនេះ លោកអ្នក នឹងត្រូវផ្តល់នូវភស្តុតាងទីពីរពីកន្លែងរស់នៅ ផងដែរ ដូចជាសារផ្លូវការ (របាយការណ៍ធនាគារ ប្រកាសពន្ធ ទស្សនាវដ្តី ។ល។) ដែលមានឈ្មោះ និងអាសយដ្ឋានរបស់លោកអ្នកនៅពីលើ។ អាសយដ្ឋាននេះត្រូវតែដូចគ្នាទៅនឹងអាសយដ្ឋានរបស់ អ្នកដែលលោកអ្នកស្នាក់នៅជាមួយ។

## <u>សូមចំណាំថា</u>

រាល់ឯកសារទាំងអស់ត្រូវតែបង្ហាញនូវឈ្មោះ និងថ្ងៃ-ខែ-ឆ្នាំកំណើត ឬការជាប់ទាក់ទង រវាងព័ត៌មាន នៅលើឯកសារ។ អាចចាំបាច់ត្រូវទាមទារឲ្យមានការផ្តល់ឯកសារបន្ថែម ប្រសិនបើការភ្ជាប់គ្នារវាងឯកសារនានា មិនអាចត្រូវបានបង្កើតឡើង (ឧទាហរណ៍ សំបុត្រអាពាហ៍ពិពាហ៍ ដីកាបញ្ជាពីតុលាការនៃការផ្លាស់ប្តូរឈ្មោះ ក្រឹត្យលែងលះ ។ល។)